នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2012, 14:45
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសេចក្តីជូនដំណឹងរួមគ្នារបស់ នួន ជា ចំពោះសំណើរបស់ អៀង សារី លេខ E234**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | | លោក សុន អរុណ |
| | | លោក Michiel PESTMAN |
| | | លោក Victor Koppe |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**<br>ពេជ អង្គ<br>Elisabeth SIMONNEAU FORT | លោក អាង ឧត្តម<br>លោក Michael G.KARNAVAS<br>លោក គង់ សំអុន<br>Anta GUISSÉ<br>លោក Arthur VERCKEN<br>លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- អស់ពេលជាងប្រាំសប្តាហ៍បន្ទាប់ពីមេធាវីការពារក្តីរបស់ អៀង សារី (“មេធាវីការពារក្តី”) បានដាក់ញត្តិទាក់ទងនឹងការសួរដេញដោលសាក្សី នង សុផង់ (Norng Sophang) ដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស)[1] និង២៥ថ្ងៃបន្ទាប់ពីសហព្រះរាជអាជ្ញាបានដាក់ការជំទាស់របស់ខ្លួនទៅនឹងញត្តិនោះ[2] មេធាវីការពារក្តីរបស់ នួន ជា (“មេធាវីការពារក្តី”) បានដាក់ញត្តិមួយមានចំនួន១៥ទំព័រ រួមគ្នាជាមួយនឹងញត្តិរបស់ អៀង សារី[3]។ សហព្រះរាជអាជ្ញាធ្វើការជំទាស់ទៅនឹងកាលបរិច្ឆេទដាក់ឯកសាររបស់ នួន ជា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែញត្តិរួមគ្នារបស់មេធាវីការពារក្តីត្រូវបានដាក់ជាឯកសារសាធារណៈ និងធ្វើឲ្យអំណះអំណាងនោះ មិនពិតប្រាកដ និងមានការយល់ច្រឡំអំពីកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានតបដូចខាងក្រោមនេះ។ ដើម្បីជៀសវាងនូវការដាក់សេចក្តីសន្និដ្ឋានច្រំដែល សហព្រះរាជអាជ្ញាដាក់បញ្ចូលឯកសារយោងដែលថាអំណះអំណាងធ្វើឡើង ក្នុងសេចក្តីជំទាស់របស់ខ្លួនទៅនឹងការរារាំងនាពេលបច្ចុប្បន្នចំពោះញត្តិរបស់មេធាវី ស្តីពីការអនុវត្តក្នុងការស្តាប់ចម្លើយសាក្សីរបស់ កសចស[4]។

---

[1] ឯកសារលេខ **E234** សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ កសចស ធ្វើការបញ្ជាក់ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ កសចស ឲ្យផ្តល់ភ័ស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយនេះ ចុះថ្ងៃទី២៧ កញ្ញា ២០១២។

[2] ឯកសារលេខ **E234/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ កសចស ធ្វើការបញ្ជាក់ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ កសចស ឲ្យផ្តល់ភស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយនេះ ចុះថ្ងៃទី៨ តុលា ២០១២។

[3] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយនិងសំណើរបស់អៀង សារី លេខ E-234, ចុះថ្ងៃទី២ វិច្ឆិកា ២០១២ (ដែលជាបន្តទៅទៀតនៅក្នុងនេះហៅកាត់ថា “ សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ”)។

[4] ឯកសារលេខ **E221/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឲ្យស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ពន្ធនឹងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ធ្វើឡើងដោយ កសចស, ចុះថ្ងៃ ទី៤ កញ្ញា ២០១២។ ឯកសារលេខ **E224/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងសុំការបញ្ជាក់ពី កសចស អំពីអត្ថិភាពនៃកំណត់ត្រាឬការថតសម្លេងនានា ទាក់ទងនឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨” ចុះថ្ងៃទី៧ កញ្ញា ២០១២។ ឯកសារលេខ **E234/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឲ្យ កសចស ធ្វើការបញ្ជាក់ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ កសចស ឲ្យផ្តល់ភស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយនេះ ចុះថ្ងៃទី៨ តុលា ២០១២ ។ ឯកសារលេខ **E241/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង “សំណើរបស់លោក អៀង សារី ស្នើសុំបើកធ្វើសវនាការសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តជាទូទៅ និងជាលក្ខណៈប្រព័ន្ធនៃការស្តាប់យកចម្លើយដោយពុំមានការថតសម្លេងឬរូបភាព” ចុះថ្ងៃ ទី១៥ វិច្ឆិកា ២០១២។

## II. **អំណះអំណាង**

### ក. កេរ្តិ៍តំណែលរបស់តុលាការនេះ គឺជាការធានាដ៏ប្រសើរបំផុត ដោយអង្គជំនុំជម្រះសាលាដំបូង និងដោយភាគី ក្នុងការប្រតិបត្តិតាមវិធាននៃច្បាប់

២- ជាដំបូង មេធាវីការពារក្តីបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងគួរតែត្រូវបានដឹកនាំដោយការព្រួយបារម្ភនានាស្តីពីកេរ្តិ៍តំណែលសម្រាប់នាពេលអនាគតរបស់ អវតក និងស្តីពីឥទ្ធិពលកេរ្តិ៍តំណែលនេះទៅលើដំណើរការជំនុំជម្រះក្តីរបស់តុលាការក្នុងស្រុក។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ចំណុចផ្តោតជាសំខាន់របស់អង្គជំនុំជម្រះបាន និងគួរតែបន្ត ការដឹកនាំដំណើរការនីតិវិធីនៃសវនាការជំនុំជម្រះក្តីត្រឹមត្រូវដែលស្របទៅតាមវិធាន និងច្បាប់ដែលគ្រប់គ្រងតុលាការនេះ។

៣- បណ្តឹងជាចំបងដែលបានលើកឡើងដោយមេធាវីការពារក្តីរបស់ អៀង សារី នៅក្នុងញត្តិរបស់ខ្លួនថ្មីៗនេះ គឺថាអ្នកស៊ើបអង្កេតរបស់ កសចស ពេលខ្លះ បានជួបនិងប្រាស្រ័យទាក់ទងជាមួយសាក្សីនានានៅមុនពេលចាប់ផ្តើមការថតសម្លេង ក្នុងការធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាផ្លូវការ។ នៅក្នុងញត្តិរួមរបស់ខ្លួន មេធាវីការពារក្តីខំស្វែងរកដើម្បីធ្វើឲ្យមានភាពដូចគ្នានូវបញ្ហានីតិវិធីតូចតាចទៅនឹងការតវ៉ាអំពីការធ្វើទារុណកម្មនៅក្នុងពេលស៊ើបអង្កេតដោយនគរបាលក្នុងស្រុក[5]។ ការណ៍នេះគឺជាសទិសភាពមានលក្ខណៈបំពាន និងជាក់ស្តែងដែលធ្វើឲ្យរាក់កំផែលដល់ការព្រួយបារម្ភអំពីសិទ្ធិមនុស្សត្រឹមត្រូវតាមច្បាប់ និងបន្ទាបដោយមិនត្រឹមត្រូវដល់អ្នកស៊ើបអង្កេតរបស់តុលាការនេះ។ មិនមានភ័ស្តុតាងតិចតួចទេដែលគាំទ្រចំពោះអំណះអំណាងថា អ្នកស៊ើបអង្កេតរបស់ កសចស បានគំរាមកំហែង, គាបសង្កត់, ឬប្រើកម្លាំង ឬការបង្ខិតបង្ខំសាក្សីដែលខ្លួនបានធ្វើសម្ភាសន៍។ ការលើកឡើងរបស់មេធាវីការពារក្តី ថាការអនុវត្តវិធានផ្ទៃក្នុង និងនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង អាចមានន័យស្មើនឹង “ការគាំទ្រ និងលើកទឹកចិត្តដល់ការអនុវត្តគ្មានគោលការណ៍របស់មន្ត្រីនគរបាល និងតុលាការក្នុងស្រុក”[6] និងជាសេចក្តីថ្លែងចាំបាច់របស់ក្រុមអ្នកច្បាប់ដែលមានឆន្ទៈនិយាយពីអ្វីមួយទោះបីស្ថិតឆ្ងាយពីការពិតក៏ដោយ ដើម្បីធ្វើឲ្យអន្តរាយដល់តុលាការនេះ។

---

[5] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី៦ (លេខយោងជើងទំព័រលេខ៥)។

[6] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី៨។

៤- ផ្អែកលើការប្រព្រឹត្តិរបស់ពួកគេរហូតមកដល់បច្ចុប្បន្ននេះ គឺមានការមន្ទិលសង្ស័យថា មេធាវីការពារក្តីរបស់ នួន ជា មានផលប្រយោជន៍ពិតប្រាកដចំពោះកេរ្តិ៍ដំណែលរបស់តុលាការនេះ។ ត្រឹមកម្រិតណាមួយនោះ មេធាវីការពារក្តីគួរតែជឿជាក់ថា ប្រសិនបើការធ្វើសម្ភាសន៍សាក្សីតាមផ្លូវតុលាការក្នុងនីតិវិធីតុលាការរបស់កម្ពុជានាពេលអនាគត ត្រូវបានធ្វើឡើង ទៅតាមនីតិវិធីដោយសុចរិត និងភាពត្រឹមត្រូវមានន័យក្នុងការធ្វើសម្ភាសន៍របស់ កសចស នៅក្នុងករណីនេះ នោះនឹងឆ្លើយតបកេរ្តិ៍ដំណែលរបស់ អវតក បានល្អហើយ។ កេរ្តិ៍ដំណែលនេះនឹងឈានមុខគេ ប្រសិនបើភាគីគោរពតាមវិធាននៃច្បាប់ និងអនុវត្តតាមវិធានផ្ទៃក្នុងរបស់តុលាការនេះ ដោយធ្វើសកម្មភាពប្រកបដោយការយកចិត្តទុកដាក់ និងដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនតាមពេលវេលាកំណត់។ ក្រុមមេធាវីការពារក្តីដែលមិនគោរពតាមវិធានផ្ទៃក្នុងរបស់តុលាការដោយឥតអៀនខ្មាស់ ហើយខកខានមិនបានគោរព ឬអនុវត្តតាមដីកាសម្រេចរបស់អង្គជំនុំជម្រះ មិនអាចត្រូវបានចាត់ទុកថាជាការជឿទុកចិត្តបានទេ នៅពេលដែលខ្លួនស្វែងរកបង្កើតកេរ្តិ៍ដំណែលរបស់តុលាការនេះ។

## ខ. ការប្រឆាំងជំទាស់របស់មេធាវីការពារក្តី ចំពោះនីតិវិធីក្នុងការធ្វើសម្ភាសន៍បានខកខានក្នុងការបង្ហាញភ័ស្តុតាងឲ្យឃើញថា បញ្ហាមានសារៈសំខាន់នានា ក្នុងលក្ខណៈត្រឹមត្រូវ ឬគួរឲ្យជឿទុកចិត្តបាននៃកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ កសចស

៥- លើសពីនេះ មេធាវីការពារក្តីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងកំពុងតែមិនគោរពទៅតាមតួនាទីរបស់ខ្លួន ក្នុងការ "ស្វែងរកការពិត" ដោយការកម្រិតការស៊ើបសួរភាពមិនប្រក្រតីដែលបានបង្ហាញនៅក្នុងនីតិវិធីនៃការធ្វើសម្ភាសន៍[7]។ ផ្ទុយទៅវិញ មេធាវីការពារក្តីមានឱកាសដើម្បីធ្វើការសួរដេញដោលចំពោះសាក្សីទាំងលើខ្លឹមសារនៃសក្ខីកម្ម និងទាំងលើនីតិវិធីបន្ទាប់ពីការធ្វើសម្ភសន៍របស់ កសចស។ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែសួរមេធាវីការពារក្តី នៅពេលតាំងសំណួរចំពោះសាក្សីលើបញ្ហានីតិវិធីសម្ភាសន៍ ត្រូវបង្ហាញពី "ការព្រួយបារម្ភនានាដែលមានមូលដ្ឋានច្បាស់ អំពីភាពគួរឲ្យជឿទុកចិត្តបាននៃនីតិវិធីនៃការស៊ើបសួរ" ជៀសវាងនូវ "សំណួរដែលជាន់គ្នា និងភាពច្រំដែល" និងប្រមែប្រមូលព័ត៌មានដែលជួយដល់អង្គជំនុំជម្រះដើម្បី "ធ្វើការសិក្សា និងពិនិត្យលើបញ្ហាខ្លឹមសារ"[8]។ ហេតុដូចនេះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការតាំងសំណួរសមហេតុសមផលចំពោះសាក្សី

[7] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី៩-១២ និង៣០-៣១។

[8] ឯកសារលេខ **E1/123.1** ប្រតិចារកនៃដំណើរការនីតិវិធីសវនាការ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១២, កថាខណ្ឌទី ៣៦-៣៧,៤៣។

ទាក់ទងអំពីនីតិវិធីក្នុងការធ្វើសម្ភាសន៍សាក្សីរបស់ កសចស ក្នុងករណីមានការសួរដេញដោលបែបនេះ គឺជួយក្នុងការបង្ហាញការពិតអំពីបញ្ហាមានសារៈសំខាន់ នៅក្នុងសំណុំរឿងលេខ០០២/០១។

៦- ទោះជាយ៉ាងណាក៏ដោយ "ការពិត" ជាសារវន្ត ដែលអង្គជំនុំជម្រះមានភារកិច្ចក្នុងការស្វែងរកការពិត គឺការពិតនៃការចោទប្រកាន់ក្នុងដីកាដំណោះស្រាយដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ ការពិតនៃការចោទប្រកាន់ទាំងនោះ នឹងមិនបង្ហាញថាតើការធ្វើសម្ភាសន៍សាក្សីជាក់លាក់ណាមួយ ដែលបានប្រើប្រាស់ពេលអស់ពីរម៉ោង ឬកន្លះថ្ងៃ ថាតើមានមានការអាក់ខានដែលមិនបានថតក្នុងការឈប់សម្រាកក្នុងការធ្វើសម្ភាសន៍ ដែលសាក្សីបានចូលទៅក្នុងបន្ទប់ទឹក និងថាតើអ្នកស៊ើបអង្កេតរបស់ កសចស បានជួប ហើយបាននិយាយគ្នាជាមួយសាក្សីនៅមុនពេលធ្វើការថតសម្លេងកំណត់ហេតុផ្លូវការដែរ ឬទេ។ ទោះបីជាមានការខិតខំប្រឹងប្រែងរួមគ្នារបស់ក្រុមមេធាវីការពារក្តី នៅក្នុងពេលសវនាការដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់គ្នាដោយពិនិត្យពិច្ច័យរវាងកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗ ជាមួយនឹងខ្សែអាត់ថតសម្លេងដែលពាក់ព័ន្ធនោះក៏ដោយ ក៏ភាពមិនស្របគ្នាដែលមេធាវីការពារក្តីបានរកឃើញ គឺវាមានចំនួនតិចតួចប៉ុណ្ណោះ ហើយដែលសាក្សីនានាបានបញ្ជាក់ជាដដែលៗ និងដោយស្របគ្នារួចហើយអំពីភាពត្រឹមត្រូវនៃខ្លឹមសារនៃចម្លើយរបស់ខ្លួន។

៧- បើសិនជា វាដូចខាងលើនេះមែននោះ មកទល់ពេលបច្ចុប្បន្ននេះ គឺមេធាវីការពារក្តីជំទាស់នឹងនីតិវិធីក្នុងការធ្វើសម្ភាសន៍សាក្សីរបស់ កសចស ខកខានក្នុងការបង្ហាញឱ្យឃើញប្រកបដោយអត្ថន័យអំពីកំហុសនានានៅក្នុងព័ត៌មានដែលបានផ្តល់ឱ្យដោយសាក្សីនោះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនមានមូលហេតុអ្វី ដើម្បីចោទសួរអំពីភាពគួរឱ្យជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃចម្លើយសាក្សីរបស់ កសចស ទៀតឡើយ។ ជាងនេះទៅទៀត ចំពោះសាក្សីដែលបានចូលមកបង្ហាញខ្លួន និងផ្តល់សក្ខីកម្មនៅក្នុងតុលាការគឺកាន់តែមានមូលហេតុតិចជាងនោះទៅទៀត ក្នុងការនិយាយច្បាស់ជាងនេះស្តីអំពីនីតិវិធីក្នុងពេលកន្លងមករបស់ខ្លួន ក្រៅពីការធ្វើសម្ភាសន៍របស់តុលាការ ដោយសារតែភាគីនានាមានលទ្ធភាពអាចធ្វើតេស្តល្បងពិសោធន៍បានអំពីសច្ចៈសីលភាពនៃចម្លើយរបស់ខ្លួន នៅក្នុងពេលសួរដេញដោលផ្ទាល់ដែលពិនិត្យមើលដោយអង្គចៅក្រមជំនុំជម្រះ។ ការពោលអះអាងរបស់មេធាវីការពារក្តីដែលថាអង្គជំនុំជម្រះសាលាដំបូងកំពុងតែ "បោះត្រាកៅស៊ូលើសេចក្តីសន្និដ្ឋានដែលនៅក្នុងដីកាដំណោះស្រាយ" ហើយមិនមានការគិតគូរអំពីថា "តើអង្គហេតុជាក់ស្តែង" ដែលខ្លួនបានរកឃើញនោះមានភាពប្រហាក់ប្រហែលគ្នានឹងការពិតនោះ"មានការធ្វេសប្រហែស និងដោយមិនមានការអនុញ្ញាត

មែនដែរឬទេ។ តាមការពិត អង្គជំនុំជម្រះគ្រាន់តែបានស្នើទៅមេធាវីការពារក្តីសុំឲ្យតាំងសំណួរស្តីពីការដែលបានចោទប្រកាន់អំពីភាពមិនប្រក្រតីទាក់ទងទៅនឹងនីតិវិធី ដើម្បីជួយនៅក្នុងការវាយតម្លៃអំពីការពិតនៅក្នុងដីកាដំណោះស្រាយតែប៉ុណ្ណោះ និងដើម្បីកុំឲ្យចំណាយពេលឥតប្រយោជន៍លើបញ្ហាបច្ចេកទេសខាងនីតិវិធីដែលតូចតាចនិងបញ្ហាក្រៅនានាដែលនៅចុងក្រោយគឺជាការខ្វល់ខ្វាយឥតអំពើ។

## គ. មេធាវីការពារក្តីគឺមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យឡើងវិញលើសំណុំរឿងនៅក្នុងអម្លុងពេលបីឆ្នាំនៃកិច្ចស៊ើបសួរ

៨- សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ខ្លួនត្រូវបានដាក់កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ និងថាកិច្ចស៊ើបសួរលើសំណុំរឿងលេខ០០២ បានបន្តធ្វើរហូតដល់ខែកក្កដា ឆ្នាំ២០១០ ហើយដីកាដំណោះស្រាយ ត្រូវបានចេញនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០។ ថ្វីបើដូច្នេះក៏ដោយ ក៏មេធាវីការពារក្តីផ្តល់នូវហេតុផលយក្សចខ្លួនថាតើមកពីហេតុអ្វីដែលខ្លួនមិនអាចធ្វើការពិនិត្យឡើងវិញឲ្យបានត្រឹមត្រូវទៅលើការធ្វើសម្ភាសន៍សាក្សីរបស់ កសចស នៅក្នុងអម្លុងពេល៣ឆ្នាំនៃកិច្ចស៊ើបសួរ។

៩- ការដោះយក្សចខ្លួនរបស់មេធាវីការពារក្តីគឺមានភាពមិនស៊ីសង្វាក់គ្នាច្រើន។ ជាដំបូង គឺមេធាវីការពារក្តីបានពោលអះអាងថាពួកខ្លួនគួរតែត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងពេលដែល កសចស ស្តាប់ចម្លើយសាក្សីដែលការចូលរួមនោះ "អាចនឹងបានជួយក្នុងការបញ្ចេញឲ្យដឹង និងជួយដោះស្រាយលើបញ្ហានានាភាគច្រើនបំផុតដែលកំពុងតែលេចឡើងទាក់ទងនិងរឿងនេះ"[9]។ ប៉ុន្តែ ជាច្រើនទំព័រក្រោយមកទៀត មេធាវីការពារក្តីបានពោលអះអាងថាពួកខ្លួនពុំមានពេលវេលាគ្រប់គ្រាន់ សូម្បីតែដើម្បីស្តាប់ខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍សាក្សីទាំងនោះក៏គ្មានដែរ នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរនោះ[10]។ បើសិនជាមេធាវីការពារក្តីអាចមានលទ្ធភាពដើម្បីធ្វើដំណើរចុះទៅតាមខេត្តនានាជាមួយអ្នកស៊ើបអង្កេតរបស់ កសចស ដើម្បីចូលរួមនៅក្នុងការធ្វើសម្ភាសន៍សាក្សីនោះ ពួកខ្លួនប្រាកដថាបានស្តាប់ខ្សែអាត់ថតសម្លេង ជាជំនួសឲ្យការចូលរួមនោះជាពុំខាន ហើយជួយសន្សំសំចៃពេលវេលានៃការធ្វើដំណើរទៅធ្វើការលើបញ្ហាផ្សេងៗទៀត។

---

[9] ឯកសារលេខ E234/2 សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី១៣។

[10] ឯកសារលេខ E234/2 សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី២១-២៦។

១០- សំណួររបស់មេធាវីការពារក្តីអំពីថាតើអង្គជំនុំជម្រះសាលាដំបូង "ក្នុងការត្រៀមរៀបចំសម្រាប់ការជំនុំជម្រះក្តី មានបានពិនិត្យមើលឡើងវិញទៅលើគ្រប់ខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយសាក្សីទាំងអស់ដែរ ឬទេ ហើយប្រសិនជាអត់បានពិនិត្យឡើងវិញទេនោះ ហេតុអ្វីបានជាមិនបានពិនិត្យមើល"[11]។ ការវាយប្រហារនេះ គឺជាការមើលមិនឃើញថាអង្គជំនុំជម្រះសាលាដំបូង មិនដូចជាមេធាវីការពារក្តីទេ គឺមិនត្រូវបានគេប្តឹងអំពីសំណុំរឿងលេខ០០២ឡើយ និងមិនត្រូវបានបើកឲ្យចូលទៅពិនិត្យមើលសំណុំរឿងរហូតទល់ពេលដែលចេញដីកាដំណោះស្រាយ។ មេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានលើបញ្ហើនៃការដោះសាររបស់ខ្លួនដោយការពោលអះអាងដោយមានជម្ងឺបែកខ្ញែកស្មារតី ថា ខ្សែអាត់ថតសម្លេងរបស់ កសចស គឺជា "សារៈសំខាន់បន្ទាប់បន្សំ" ហើយហេតុដូចនេះគឺជាការត្រឹមត្រូវដែលត្រូវបានគេធ្វើមិនដឹងមិនឮនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ប៉ុន្តែថាភ័ស្តុតាងដដែលនេះឥឡូវនេះមានភាព"សំខាន់ចាំបាច់ខានមិនបាន"សំរាប់គោលបំណង ដើម្បីការសួរដេញដោយចំពោះសាក្សីរបស់ភាគីបដិបក្ខនៅក្នុងសវនាការ[12]។

១១- ការឆ្លើយទៅនឹងសំណួរដែលចោទសួរដោយអង្គជំនុំជម្រះសាលាដំបូង អំពីថាតើមេធាវីការពារក្តីបាននឹងកំពុងធ្វើអ្វីខ្លះនៅក្នុងអម្លុងពេល៣ឆ្នាំនៃកិច្ចស៊ើបសួរ អាចត្រូវបានមើលឃើញថា ជាការពិនិត្យមើលសំណុំរឿងឡើងវិញដោយផ្ទាល់។ ជាជាងការត្រៀមរៀបចំសំរាប់សវនាការដោយការពិនិត្យឡើងវិញ

ទៅលើភ័ស្តុតាងនិងកំណត់អត្តសញ្ញាណកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដោយឡែកណាម្នាក់ដែលមានការជាប់ទាក់ទងនឹងកូនក្តីរបស់ខ្លួន មេធាវីការពារក្តីបានសំរេចចិត្តក្នុងការចំណាយពេលរបស់ខ្លួន ដើម្បីដាក់សំណើ, ញត្តិ, និងបណ្តឹងឧទ្ធរណ៍មួយចំនួនដោយគ្មានមូលដ្ឋានត្រឹមត្រូវទាក់ទងនឹងកិច្ចស៊ើបសួរទៅវិញ ក្នុងការខិតខំប្រឹងប្រែងដ៏ច្បាស់ក្រឡែតដើម្បីអូសបន្លាយពេលនៃរឿងក្តីនិងទប់ស្កាត់កុំឲ្យឈានទៅដល់ការជំនុំជម្រះក្តីនោះ។ មេធាវីការពារក្តីបានទទួលលស្គាល់ដោយខ្លួនឯងថា ខ្លួនបានដាក់សំណើចំនួន២៦សុំឲ្យបំពេញកិច្ចស៊ើបសួរដែលក្នុងនោះរួមមាន បានសុំឲ្យ កសចស ធ្វើការស៊ើបសួរអំពីកំរិតនៃការចូលរួមរបស់ប្រទេសចិន "កម្រិតនៃការគ្រប់គ្រងរបស់ប្រទេសចិនមកលើរដ្ឋា

[11] ឯកសារលេខ E234/2 សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី១៣ (លេខយោងជើងទំព័រលេខ១៨)។

[12] ឯកសារលេខ E234/2 សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី២៦។

ភិបាលនៃកម្ពុជាប្រជាធិបតេយ្យ" និងអំពីថាតើរដ្ឋរបស់បរទេសចំនួន១១ គឺ (វៀតណាម ចិន សហរដ្ឋអាមេរិក ថៃឡង់ បារាំង រុស្ស៊ី កូរ៉េខាងជើង ឡាវ គុយបា អាល់បានី និងយូហ្គោស្លាវី ) "មានបានធ្វើប្រតិបត្តិការបណ្តាញភ្នាក់ងារសម្ងាត់នៅក្នុងទឹកដីនៃកម្ពុជាប្រជាធិបតេយ្យដែរ ឬទេ"[13]។ មេធាវីការពារក្តីក៏បានដាក់ញត្តិចំនួន១៧ផ្សេងទៀតយ៉ាងតិច ឬសំណើសុំទៅ កសចស[14] បណ្តឹងឧទ្ធរណ៍ចំនួន១៦ ទៅអង្គបុរេជំនុំជម្រះ[15] នៅក្នុងអម្លុងពេលនៃដំណាក់កាលមុនការជំនុំជម្រះក្តី។

១២- ក្នុងខណៈដែលមានការដាក់ឯកសារដ៏ទូលំទូលាយដោយមេធាវីការពារក្តីបែបនេះ បានចំណាយពេលវេលានិងធនធានយ៉ាងច្រើន នៅក្នុងអម្លុងនៃកិច្ចស៊ើបសួរ ពួកគេបានដាក់បន្ថែមដ៏តិចតួច (ឬមិនមានអ្វីទាល់តែសោះ) ដែលមានតម្លៃដែលមានសារៈសំខាន់ចូលនៅក្នុងសំណុំរឿង។ ទោះបីជាយ៉ាងណាក្តី សហព្រះរាជអាជ្ញា សូមជូនជាមតិថា ការប្រើក្រដាសស្នាមដ៏ច្រើនហួសហេតុនៅក្នុងការដាក់ឯកសារដោយមេធាវីការពារក្តីនៅក្នុងអម្លុងពេលនៃដំណាក់កាលមុនសវនាការគឺជាមូលហេតុជាចំបងដែលថាមេធាវីការពារក្តីមានការយកចិត្តទុកដាក់ដ៏តិចតួចបំផុតចំពោះការស្តាប់ចម្លើយសាក្សី ដែលបានបើកធ្វើដោយ កសចសនៅក្នុងរយៈពេលជាមួយគ្នានេះ។

## ឃ. វិធានផ្ទៃក្នុងរបស់ អវតក មិនតម្រូវឱ្យធ្វើការថតសម្លេង/វីដេអូ នៃការស្តាប់ចម្លើយសាក្សីនោះទេ

១៣- ជាអ្នកចូលរួមដាក់សំណើរតវ៉ា ដោយមេធាវីការពារក្តីដែលគួរតែទទួលយកត្រង់ចំណុចមួយ ថា មេធាវីការពារក្តីរបស់ អៀង សារី បានចចេសបដិសេធមិនព្រមទទួលស្គាល់-ថាវិធាន២៥នៃវិធានផ្ទៃក្នុងមិនបានតម្រូវថា ការស្តាប់ចម្លើយសាក្សីដោយ កសចស ត្រូវតែមានការថតសម្លេង ឬវីដេអូនោះ

---

[13] ឯកសារលេខ **D101** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើកទីបី, ចុះថ្ងៃទី១៨ សីហា ២០០៨, កថាខណ្ឌទី១១ [ប្រទេសចិន]។ឯកសារលេខ **D102** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើកទីបួន, ចុះថ្ងៃទី២៧ សីហា ២០០៨, កថាខណ្ឌទី៩ [ប្រទេសវៀតណាម]។ឯកសារលេខ **D105** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើកទីបួន, ចុះថ្ងៃទី២៦ កញ្ញា ២០០៨, កថាខណ្ឌទី១០ [សហរដ្ឋអាមេរិក]។ឯកសារលេខ **D126** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើកទីប្រាំបី, ចុះថ្ងៃទី២១ មករា ២០០៩, កថាខណ្ឌទី៨ [ប្រទេសថៃ]។ ឯកសារលេខ **D128** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ លើកទីប្រាំបី, ចុះថ្ងៃទី២៧ មករា ២០០៩, កថាខណ្ឌទី៨ [ប្រទេសសបារាំង, រុស្ស៊ី, ប្រទេសចិន, វៀតណាម, កូរ៉េខាងជើង, ឡាវ, គុយបា, អាល់បានី និង យូហ្គោស្លាវី]។

[14]ឯកសារលេខ D54; D55; A158; A169; A186; A201; A195; A202; D114; D116; D100/4; D124; D171/2; D235; D254; D384; C65.

[15] ឯកសារលេខ C11/4; D55/I/1; D54/V/1; C33/I/3; C9/4/1; D158/5/1/1; D164/4/1; D100/9/1; D300/1/1; D253/3/1; D315/1/1; D314/2/4; D273/3/2; D356/2/1; D375/1/1; D384/5/1.

ឡើយ[16]។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីគឺមិនត្រឹមត្រូវទេដោយបានលើកឡើងថាមន្ត្រីស៊ើបអង្កេតរបស់ កសចស ត្រូវតែ កត់ត្រាអំពីរយៈពេលនៃការស្តាប់ចម្លើយ និងការសំរាក ដោយសារមូលហេតុដូចដែលបានគូសបញ្ជាក់យ៉ាងលំអិតនៅក្នុងការដាក់សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញាថ្មីៗនេះ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២[17]។

១៤- ការអនុវត្តរបស់មន្ត្រីស៊ើបអង្កេតរបស់ កសចស ខ្លះ ក្នុងការជួបប្រជុំពិភាក្សាជាបឋមជាមួយសាក្សីនានា នៅមុនពេលចាប់ផ្តើមធ្វើការថតសម្លេង/វីដេអូ/ធ្វើកំណត់ហេតុជាផ្លូវការ គឺមិនមែនជាការរំលោភលើវិធានផ្ទៃក្នុងរបស់ អវតក នោះទេ ហើយមិនគួរឲ្យមានការមន្ទិលសង្ស័យឡើយ នេះគឺជាការបម្រើដើម្បីធានាឲ្យមានការប្រាស្រ័យទាក់ទងជាមួយសាក្សីកាន់តែប្រសើរជាងមុន និងការធ្វើកំណត់ហេតុជាលាយលក្សណ៍កាន់តែត្រឹមត្រូវថែមទៀត។ ភាពមិនច្បាស់លាស់របស់មេធាវីការពារក្តីដែលថា ការប្រជុំដោយគ្មានការថតជាសម្លេង/វីដេអូ ទាំងនេះមានដោយមានគោលបំណងអាក្រក់មួយចំនួននោះ គឺមិនមានការចង្អុលបង្ហាញភស្តុតាងដោយភស្តុតាងមួយចំនួនណានោះឡើយ ហើយត្រូវបានឆ្លើយបដិសេធជាដដែលៗដោយសាក្សីម្នាក់ៗ ដែលត្រូវបានសួរដេញដោលលើប្រធានបទនេះ។

១៥- ជាងនេះទៀត ឥឡូវនេះ មេធាវីការពារក្តី បានលើកឡើងអះអាងថា គោលបំណងនៃការដាក់ឯកសាររបស់ខ្លួនគឺមិនមែន "ដើម្បីតវ៉ាអំពីពួកមន្ត្រីស៊ើបអង្កេត ដែលខកខានមិនបានថតសម្លេង/វីដេអូនៃការស្តាប់ចម្លើយសាក្សីខ្លះៗ ឬផ្នែកនៃការធ្វើស្តាប់ចម្លើយ *បែបនេះនោះទេ* ហើយក៏មិនមែនដើម្បី "តវ៉ាអំពីមន្ត្រីស៊ើបអង្កេត ដែលខកខានមិនបាន កត់ត្រាអំពីរយៈពេលនៃការស្តាប់ចម្លើយសាក្សីខ្លះ *បែបនេះ* នោះក៏ទេដែរ"[18]។ បើសិនជាករណីដូចខាងលើនេះមែននោះ គេមុខជានឹងរំពឹងថា ការតាំងសំណួរដេញ

[16] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី១១៥-១៦។*សូមអានផងដែរ* ឯកសារលេខ **E241/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើរបស់លោក អៀង សារី ស្នើសុំបើកធ្វើសវនាការសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធ នឹងទម្លាប់អនុវត្តជាទូទៅ និងជាលក្ខណៈប្រព័ន្ធនៃការស្តាប់យកចម្លើយដោយពុំមានការថតសម្លេងឬរូបភាព" ចុះថ្ងៃ ទី១៥ វិច្ឆិកា ២០១២ , កថាខណ្ឌពីទី២៨-២៩។ ឯកសារលេខ **E142/3** សេចក្តីសំរេចលើសំណើសុំឲ្យបំបេញកិច្ចស៊ើសួររបស់នួនជា ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងទាក់ទងនឹងភាពពុំត្រឹមត្រូវនៅក្នុងកំត់ហេតុជាលាយលក្សណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស, ចុះថ្ងៃទី១៣ មិណា ២០១២, កថាខណ្ឌទី៦, លេខយោងជើងទំព័រលេខ១៣។

[17] ឯកសារលេខ **E241/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើរបស់លោក អៀង សារី ស្នើសុំបើកធ្វើសវនាការសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តជាទូទៅនិងជាលក្ខណៈប្រព័ន្ធនៃការស្តាប់យកចម្លើយដោយពុំមានការថតសម្លេងឬរូបភាព" ចុះថ្ងៃ ទី១៥ វិច្ឆិកា ២០១២ , កថាខណ្ឌពីទី២៤-២៧។

[18] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី១៩។

ដោលសាក្សីរបស់ មេធាវីការពារក្តីមុខជានឹងត្រូវបានកម្រិតត្រឹមតែការបង្ហាញភស្តុតាងថាពួកគេគ្រាន់តែបានជួប និងបាននិយាយជាមួយនឹងមន្ត្រីស៊ើបអង្កេតរបស់ កសចស នៅក្នុងឱកាសផ្សេងទៀត នៅមុន ឬក្រោយពេលនៃការថតសម្លេង/វីដេអូ/ធ្វើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាផ្លូវការតែប៉ុណ្ណោះ ហើយតើថា រយៈពេលសរុបនៃការថតសម្លេងតិចជាងពេលវេលារវាងការមកដល់ និងការចេញដំណើររបស់មន្ត្រីស៊ើបអង្កេតដែរ ឬក៏អត់នោះទេ។ ប៉ុន្តែ តាមការពិតក្រុមមេធាវីការពារក្តីជាទូទៅបានជៀសវាងក្នុងការសួរទៅសាក្សីនូវសំណួរណា ដែលបង្ហាញអោយឃើញថាតើមានសារៈសំខាន់ណាមួយចំពោះការប្រាស្រ័យទាក់ទងជាមួយ កសចស ដែលមិនមានការថតសម្លេងដែរ ឬទេ- ឧទាហរណ៍ដូចជាថា នៅក្នុងអម្លុងនៃឱកាសបែបនេះ តើពួកគេមានត្រូវបានណែនាំឲ្យនិយាយឬត្រូវបានគេធ្វើការគៀបសង្កតដែរ ឬក៏អត់ តើពួកគេមានបានផ្តល់ព័ត៌មានផ្សេងទៀតទៅឲ្យពួកមន្ត្រីស៊ើបអង្កេតដែលមិនបានកត់ត្រានៅក្នុងកំណត់ហេតុស្តីពីការស្តាប់ចម្លើយពួកគេដែរ ឬទេ។ សហព្រះរាជអាជ្ញាជូនជាយោបល់នេះ ព្រោះមិនមាន "មូលដ្ឋានត្រឹមត្រូវ" ទាល់តែសោះ ដើម្បីឲ្យជឿថាមានអ្វីមួយដែលមិនត្រឹមត្រូវបានកើតឡើងនៅក្នុងឧកាសនោះឡើយ។

## ង. ពាក្យបណ្តឹងទូទៅរបស់មេធាវីការពារក្តីស្តីពីភាពមិនត្រឹមត្រូវ គឺពុំត្រូវបានគេរកឃើញនោះទេ

១៦- ចុងបញ្ចប់ មេធាវីការពារក្តីបានធ្វើការចោទប្រកាន់មួយចំនួនថាអង្គជំនុំជម្រះសាលាដំបូង បានអោយតម្លៃពួកគេមិនស្មើរមុខជាមួយភាគីដ៏ទៃទៀតនោះទេ ដែលបញ្ហានេះត្រូវបានសហព្រះរាជអាជ្ញាលើកឡើងថា វាពុំត្រូវបានគេរកឃើញដូចការចោទប្រកាន់នោះទេ[19]។

១៧- ជាឧទាហរណ៍ មេធាវីការពារក្តីបានអះអាងថា នៅពេលដែលពួកគេបានលើកពីអញ្ញត្រកម្មពាក់ព័ន្ធនឹងយថាភាព និងខ្សែសង្វាក់នៃការគ្រប់គ្រងភស្តុតាងជាឯកសារ ចម្លើយតបតែមួយគត់របស់អង្គជំនុំជម្រះសាលាដំបូងនោះ គឺការតវ៉ាអំពីភាពមិនចំពេលវេលានៃអញ្ញត្រកម្ម និងការមិនទទួលដឹងពីខ្លឹមសារនៃបញ្ហា[20]។ ការអះអាងនេះ គឺខុសទាំងស្រុង។ តាមការពិត អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន៦ថ្ងៃ នៅលើបញ្ហាទាំងនេះ ហើយបានធ្វើសវនាការជាច្រើនដង ដោយបានពិចារណាទៅលើ អញ្ញត្រកម្មទាំងនោះ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

[19] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី២៧-២៩។

[20] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី២៨។

សាលាដំបូងទាក់ទងនឹងការទទួលយកឯកសារ គឺមានមូលដ្ឋាននៅលើសវនាការ និងខ្លឹមសារនៃសារណារបស់ភាគីទាំងនេះ មិនមែននៅ លើភាពមិនចំពេលវេលានៃអញ្ញត្រកម្មរបស់មេធាវីការពារក្តីនោះទេ។

១៨- មេធាវីការពារក្តីក៏បានតវ៉ាអំពីការបដិសេធដ៏មិនចេះនឿយហត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុញ្ញាតិអោយមេធាវីការពារក្តីផ្អែកលើឯកសារជាលាយលក្ខអក្សរនានាដែលមិនបានជូនដំណឹងកាលពីខែមេសា ឆ្នាំ២០១១[21]។ មេធាវីការពារក្តីមិន បានលើកឡើងថាវាមិនស្របទៅនឹងលំដាប់លំដោយនៃការរៀបចំសវនាការតំបូងរបស់អង្គជំនុំជម្រះ ដែលបង្គាប់ឲ្យគ្រប់ភាគីទាំងអស់ធ្វើការកំណត់អត្តសញ្ញាណឯកសារ ដែលពួកគេមានបំណងបង្ហាញនៅពេលសវនាការ កាលពីខែមេសា ឆ្នាំ២០១១[22] និងកាលានុវត្តភាពលើកទីពីរមួយទៀត ដែលគេបានផ្តល់ឲ្យទៅមេធាវីការពារក្តីដើម្បីឲ្យផ្តល់បញ្ជីឯកសារសម្រាប់សវនាការ កាលពីខែកក្កដា ឆ្នាំ២០១១[23]។ នៅក្នុងករណីទាំងពីរនេះ មេធាវីការពារក្តីបានបដិសេធមិនព្រមផ្តល់បញ្ជីឯកសារណាមួយឡើយ ដោយបានអះអាងថាពួកគេមិនមានកាតព្វកិច្ចផ្តល់ដំណឹងជាមុនអំពីឯកសារ ដែលពួកគេមានបំណងនឹងប្រើប្រាស់នៅពេលសវនាការនោះទេ[24]។ ថ្វីបើមានការបដិសេធរបស់ពួកគេ ដែលមិនព្រមធ្វើតាមវិធានតែមួយដូចគ្នានឹងភាគីផ្សេងទៀតក៏ដោយក៏នៅពេលសវនាការ គេនៅតែអនុញ្ញាតឲ្យមេធាវីការពារក្តីប្រើប្រាស់នូវឯកសារដែលពួកគេមិនបានដាក់បង្ហាញពីមុនមក ជាដដែល នៅពេលដែលវាមានលក្ខណៈ ស្របតាមវិធាន៨៧.៤ ត្រូវបានដាក់ឬបើពុំដូច្នោះទេ ឯកសារទាំងនោះ គឺ "ត្រូវមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីអាចទទួលយក បើទោះបីជាមានការដាក់យឺតយ៉ាវក៏ដោយ[25]។

១៩- មេធាវីការពារក្តីបានតវ៉ាថា ពួកគាត់ត្រូវបានគេតិទៀនអំពីការដែលបានលើកឡើងនូវសិទ្ធិក្នុងការមិនធ្វើពិរុទ្ធកម្មលើខ្លួនឯងរបស់សាក្សី នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ[26] ក៏ប៉ុន្តែបាន

[21] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, ជើងទំព័រ៣០។

[22] ឯកសារលេខ **E9** ដីកាសម្រេចដាក់ឯកសារសម្ភារៈសម្រាប់ការរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ , កថាខណ្ឌទី១២។

[23] ឯកសារលេខ **E1/4.1** ប្រតិចារឹកសវនាការបឋម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ លេខឯកសារE00៧១២១៦១។

[24] ឯកសារលេខ **E9/26** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ នៅក្នុងការស្នើសុំដំបូងរបស់ អៀង សារី ទាក់ទងនឹងឯកសារសុំប្រើប្រាស់នៅពេលសវនាការ និងការស្នើសុំបន្ថែមទាក់ទងនឹងឯកសារថ្មី ចុះថ្ងៃទី១៩ មេសា ២០១១, កថាខណ្ឌទី២។ **E109/3** សេចក្តីអង្កេតទាក់ទងនឹងឯកសារទាំងឡាយដែលគេចាត់ទុកថា ទាក់ទងទៅនឹងដំណាក់កាលដំបូងនៃសវនាការ ថ្ងៃទី២២ កក្កដា ២០១១ កថាខណ្ឌ១-២ (គ) ៥។

[25] ឯកសារលេខ **E190** សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ មេសា ២០១២ កថាខណ្ឌ៣៥-៣៧។

[26] ឯកសារលេខ **E234/2** សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយ, កថាខណ្ឌទី២៨(ទំព័រ១៣)។

ប្រមើលមើលថាការតិទៀននេះ គឺមកពីកិច្ចអន្តរាគមន៍របស់ពួកគេដែលបានធ្វើឡើង នៅពេលមានវត្តមានរបស់សាក្សី ដោយគាត់ត្រូវឆ្លើយតបទៅនឹងកំរងសំណួរដ៏សំខាន់មួយចំនួនដែលអាចបង្កើតនូវព័ត៌មានដែលអាចធ្វើឲ្យមានការខូចខាតដល់ នួន ជា។ ដោយមកពីកិច្ចអន្តរាគមន៍របស់មេធាវីការពារក្តីមិនមានពាក់ពន្ធ័ទៅនឹងសំណួរណាមួយដែលដាក់ពិរុទ្ធលើសាក្សី ប៉ុន្តែបែជាមានសំណួរដែលដាក់ពិរុទ្ធទៅលើកូនក្តីរបស់ខ្លួនឯងទៅវិញ វាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា គោលបំណងពិតប្រាកដនៃកិច្ចអន្តរាគមន៍នោះ គឺជាការប៉ុនប៉ងគំរាមកំហែងដល់សាក្សី និងធ្វើមិនឲ្យគាត់បានផ្តល់សក្ខីកម្ម[27]។

២០- ដូច្នេះ វាពុំមានអង្គសេចក្តីទេចំពោះការដែលមេធាវីការពារក្តីបានអះអាងថាពុំមានការប្រព្រឹត្តិត្រឹមត្រូវពីសំណាក់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។

## III. សេចក្តីសន្និដ្ឋាន

២១- ចំពោះមូលហេតុនានាដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ញត្តិរួមរបស់ អៀង សារី និងញត្តិចូលរួមគាំទ្ររបស់ នួន ជា គួរត្រូវបានបដិសេធចោល។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[27] ឯកសារលេខ **E1/63.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ ថ្ងៃទី១៨ មេសា ២០១២ កថាខណ្ឌ៣៣-៣៥ និង ៤៣-៤៤។